ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៣០
ចុះថ្ងៃទី០៥-០៦-០០
សាលដីកាលេខៈ ១៩
ចុះថ្ងៃទី២៥-០៤-២០០១

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅៈ

១-ឯកឧត្តម... ប្រធាន
២-លោក... ចៅក្រម
៣-លោក... ចៅក្រម
៤-លោក... ចៅក្រម
៥-លោក... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
លោក...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០-០៤-២០០០ របស់លោក... ការពារជនជាប់ចោទ ដែលប្តឹងតវ៉ា ពីសាលដីកាព្រហ្មទណ្ឌ លេខ៩៩ ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេច

ទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ៣០ ចុះថ្ងៃទី០៥-០៦-២០ ០០ របស់តុលាការកំពូល។

-ជនជាប់ចោទឈ្មោះ **វរ** ភេទស្រីអាយុ២៦ឆ្នាំជាតិខ្មែរ កើតនៅសង្កាត់លេខ៣ក្រុងភ្នំពេញទីលំនៅសព្វថ្ងៃ ផ្ទះលេខ២៥១ ផ្លូវ២៨២ ក្រុមទី២០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោកក្រុងភ្នំពេញ។ ឪពុកឈ្មោះ...ម្ដាយឈ្មោះ...ប្ដីឈ្មោះ...មានកូន០២នាក់ ចាប់ខ្លួនថ្ងៃទី០៥-០៥-៩៩។

-ត្រូវចោទពីបទៈ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៣-០២-៩៩តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-មេធាវីលោក...

-ដើមបណ្ដឹងរដ្ឋប្បវេណីលោក **យយណ** ជាតិខ្មែរ បច្ចុប្បន្នប្រធាននាយកដ្ឋានទំនាក់ទំនងវប្បធម៌ នៃក្រសួងអប់រំមានទីលំនៅផ្ទះលេខ៧២ ផ្លូវ៥៨៤ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោកក្រុងភ្នំពេញ។

-មេធាវីគ្មាន

-តាមបណ្ដឹងសាទុក្ខលេខ២០ចុះថ្ងៃទី២០-០៤-២០០០របស់លោក...ការពារឱ្យជនជាប់ចោទ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៩៩ ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល។

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៦-០៣-៩៩ របស់លោក **យយណ** ប្ដឹងពីឈ្មោះ **វរ និង វណឡ** ព្រោះ ថាមានភស្ដុតាង រូបថតចំនួន០៨សន្លឹកនិងកាសែតវីដេអូពីរ ដែលទាក់ទង ដល់ឈ្មោះ **វរ និង វណឡ** បានទាំចោរប្លន់ផ្ទះលេខ៧២ ផ្លូវ៥៨៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-០២-៩៩។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញសម្រេច ចោទប្រកាន់លើឈ្មោះ ***វវ*** ភេទស្រី អាយុ២១ឆ្នាំ ពីបទឃាដកម្មគិតទុកជាមុននិងប្លន់ទ្រព្យសម្បត្តិប្រជាជន ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី២៣-០២-១៩៩៩ បទល្មើស ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣១,៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញ ដីកាសម្រេចលេខ៥២៣៦តព្រចុះថ្ងៃទី២៦-១១-១៩៩៩ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ដែលមានសេចក្តីសម្រេចដូចតទៅ៖

១-បដិសេធពាក្យសុំឱ្យលើកលែងចោទប្រកាន់ ចុះថ្ងៃទី០៦-០៩-១៩៩៩ និងពាក្យសុំដោះលែងឱ្យមានសេរីភាពចុះថ្ងៃទី១៧-០១-១៩៩៩ របស់មេធាវីឈ្មោះ...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ ***វវ*** ភេទស្រី អាយុ ២១ ឆ្នាំ ជាតិខ្មែរ ទីនៅផ្ទះលេខ២៥១ ផ្លូវទេពផន ក្រុម២ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ចោលជាអសារបង់ចាប់ពីពេលនេះតទៅ។

២-សេចក្តីសម្រេចនេះ បើកការប្តឹងឧទ្ធរណ៍រយៈពេល០៥ថ្ងៃ ចាប់ពីពេលទទួល ដំណឹងតទៅ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ២២ចុះថ្ងៃទី២៤-១២-១៩៩៩របស់លោក...ដែលប្តឹងពីដីកាសម្រេចលេខ៥២៣៦ចុះថ្ងៃទី២៦-១១-១៩៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍នាពេលសវនាការថា បដិសេធបណ្តឹងឧទ្ធរណ៍លេខ២២ចុះថ្ងៃទី២៤-១២-៩៩ របស់មេធាវី... ចោលជាអសារបង់ដោយខុសនឹងទម្រង់ច្បាប់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៩៩ ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-មិនទទួលជំនុំជម្រះបណ្ដឹងឧទ្ធរណ៍លេខ២២ ចុះថ្ងៃទី២៤-១២-៩៩ របស់លោក...ជាមេធាវីការពារជនជាប់ចោទ ដោយបណ្ដឹងឧទ្ធរណ៍នេះធ្វើឡើងខុសនឹងទម្រង់ច្បាប់។

២-បង្វិលសំណុំរឿង នេះទៅតុលាការសាម៉ុ ដើម្បីចាត់ការបន្ដតាមនីតិវិធី។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

៤-សាលដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្ដឹងសាទុក្ខក៏ដោយ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០-០៤-២០០០ របស់លោក...តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៩៩ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី២៩-០៦-២០០០ របស់លោក... មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ ***វវ*** ជាម្ចាស់បណ្ដឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី២៤-០៧-២០០០ របស់លោក **ឃឃណ** ជាចុងបណ្ដឹងសាទុក្ខធ្វើឡើងក្នុង កំណត់ច្បាប់។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

១-បណ្តឹងសាទុក្ខរបស់លោក...ស្ថិតក្នុងកំណត់ច្បាប់គប្បីលើកមកពិនិត្យពិចារណា។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩៩ ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

-បានស្តាប់ជនជាប់ចោទឈ្មោះ **វវ** បានអះអាងនាពេលសវនាការថា៖ ខ្លួនពុំបានដឹង ឮនិងចូលរួមប្រព្រឹត្តបទល្មើសមនុស្សឃាតដោយប្រយោលក្តី ដោយផ្ទាល់ក្តី គឺដើមចោទប្តឹងខ្លួន ដូច្នេះពុំត្រឹមត្រូវឡើយ ព្រោះរឿងកើតហេតុខ្លួន មិនបាននៅទីនោះដែរ សូមតុលាការកំពូល ជួយរកយុត្តិធម៌ឱ្យខ្លួនផង។

-ជូនស្តាប់ លោក **យយណ** ដើមបណ្តឹងថា នៅថ្ងៃទី២៣-០៤-៩៩ មានចោរប្លន់០៤នាក់ ដឹកនាំដោយឈ្មោះ **វវ** ត្រូវជាប្អូនថ្លៃរបស់ឈ្មោះ **ឈឈ** ចូលប្លន់ក្នុងផ្ទះរបស់ខ្លួនក្នុងសង្កាត់បឹងកេងកង ហើយសម្លាប់ភរិយាខ្លួន បងថ្លៃស្រីនិង ក្មួយស្រី២នាក់ ទៀតរបស់ខ្លួនយ៉ាងព្រៃផ្សៃបំផុត តែដោយភព្វសំណាងបងស្រីខ្លួនឈ្មោះ **សណដរ** រួចផុតពីសេចក្តីស្លាប់ ដោយចោររិតកមិនស្លាប់ បញ្ជូនទៅមន្ទីរសង្គ្រោះជាបន្ទាន់ នៅឯមន្ទីរពេទ្យកាល់ម៉ែត។ នៅពេលបងថ្លៃស្រីខ្លួន ដឹងខ្លួន ទើបសមត្ថកិច្ច ធ្វើការស្រាវជ្រាវដឹងថាឃាតករឈ្មោះ **វវ** និងមានគ្នាពីរបីនាក់ទៀត។ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តារកយុត្តិធម៌កាត់ទោសជនល្មើសតាមច្បាប់។

-បានស្តាប់មេធាវីលោក...ការពារឱ្យជនជាប់ចោទឈ្មោះ **វវ** សន្និដ្ឋានទាពេលសវនាការថា រឿងហេតុ ដែលកើតមានឡើង ត្រូវបានព្រះរាជអាជ្ញា មានការសង្ស័យ ចោទប្រកាន់លើឈ្មោះ **វវ** ដើម្បីស៊ើបអង្កេតនោះមានរយៈពេល

ជាង៨ខែហើយពុំ មានឃើញភស្តុតាងណាមួយដាក់បន្ទុកលើកូនក្តីខ្លួនទាល់តែសោះ ទើបខ្លួនដាក់ពាក្យសុំឱ្យតុលាការ ដោះលែងយោងទៅតាមអំណាចមាត្រា១ នៃច្បាប់ស្តីពីការឃុំខ្លួន បណ្តោះអាសន្ន ដែលរដ្ឋសភា ទើបតែអនុម័ត។ការដែលតុលាការមិនព្រមដោះលែងទៀត ទើបខ្លួនដាក់ពាក្យធានាឱ្យនៅក្រៅឃុំបណ្តោះអាសន្ន និងសុំលើកលែងចោទប្រកាន់នូវការធានាគ្រប់យ៉ាងពីមេធាវី តែតុលាការបានចេញដីកាសម្រេចលេខ៥២៣៦ តព្រ ចុះថ្ងៃទី២៦-១១-៩៩ទើបខ្លួនប្តឹងឧទ្ធរណ៍នឹងដីកានេះតាមកំណត់ច្បាប់។ ក្នុងនាមខ្លួន ជាអ្នកការពារឱ្យជនជាប់ចោទ សូមលើកពីធាតុផ្សំបញ្ជាក់លើកត្តាពីរគឺ ការចូលរួមប្រព្រឹត្តជាក់ស្តែង ឬការធ្វើសកម្មភាព,ផលវិបាកកើតឡើងពីសកម្មភាពនោះ។ ដូច្នេះបើនិយាយពីសកម្មភាពវិញ កូនក្តីខ្លួនឈ្មោះ **វវ** ពុំបានចូលរួមប្រព្រឹត្តបទល្មើសឡើយ ទោះជាដោយផ្ទាល់ ដោយប្រយោលក៏ដោយ កូនក្តីខ្លួនពុំបានដឹងអ្វីទាំងអស់ សូមប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចដោះលែងកូនក្តីខ្លួនបាននៅក្រៅឃុំជាបណ្តោះអាសន្ន។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការអមតុលាការកំពូលនាពេលសវនាការថា៖ ពុំមានអ្វីក្នុងការបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួននៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវ តាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០-០៤-២០០០ របស់មេធាវីជនជាប់ចោទធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន ដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា មេធាវីជនជាប់ចោទបានប្តឹងឧទ្ធរណ៍ ដោយគ្មានការប្រគល់សិទ្ធិពីជនជាប់ចោទនៅថ្ងៃទី២៤-១២-៩៩ ហើយដែលមេធាវីបានទទួលដីកាសម្រេចលេខ៥២៣៦ តព្រ ចុះថ្ងៃទី២៦-១១-៩៩ នៅថ្ងៃទី៣០-១១-៩៩។ ដូច្នេះមេធាវីជនជាប់ចោទ បានប្តឹងឧទ្ធរណ៍ហួសកំណត់ដែលបានកំណត់ក្នុងមាត្រា១៤ច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងបំពានទៅលើមាត្រា១៦២ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ៩៩ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់នឹងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទនិងដើមរដ្ឋប្បវេណី

១-ទទួលបណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០-០៤-២០០០ របស់មេធាវីជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ប៉ុន្តែ បដិសេធចោល ដោយខុសនឹងគតិច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩៩ចុះថ្ងៃទី០៧-០៤-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០១ ។